# ផ្តេរទ្វារនៅវត្តសូភាស

វត្តសូភាស មានទីតាំងស្ថិតនៅភូមិសូភាស ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលមានចម្ងាយប្រមាណ ៣គ.ម. ខាងត្បូងផ្លូវជាតិលេខ៧០ បត់ចូលតាមឃុំមេសរជ្រៃ ប៉ែកខាងត្បូងភូមិសូភាស។ វត្តនេះ គឺជាអតីតទីតាំងប្រាសាទបុរាណនៅសម័យមុនអង្គរ (ស.វ.ទី៧) ដែលមានតួប៉មសរុបចំនួន ៣ ប៉ុន្តែតួប៉មទាំងអស់បានដួលរលំបាត់អស់ទៅហើយ។[១] ក្រៅពីនេះ នៅជុំវិញវត្តសូភាស មានអាងស្តុកទឹកបុរាណមួយចំនួនទៀត ដូចជា ទន្លេអុំ ត្រពាំងព្រះ ត្រពាំងស្រង់។

អ្នកស្រុកតែងគិតថាឈ្មោះ “**សូភាស**” គឺកើតចេញពីរឿងព្រេងចំនួនពីរដែលគេតែងនិទានតៗគ្នា។ រឿងព្រេងទីមួយ ដំណាលថា “*កាលពីដើមមកមានតាបសម្នាក់ ដែលទំនងជាមេទ័ព រួមជាមួយយាយ ភាស បានភៀសខ្លួនចេញពីសង្គ្រាមមកជ្រកកោននៅទីនេះ ហើយក៏ចាប់ផ្តើមសាងជាអាស្រមនៅពេលស្រុកទេសប្រសើរវិញ។ ក្រោយមក គេក៏ហៅទីនេះថា “សូភាស”*។ រឿងព្រេងទីពីរ ដំណាលថា “*មានមេទ័ពម្នាក់បានភៀសខ្លួនចេញពីសង្គ្រាមនៅក្រុងឧដុង្គ មកកាន់ទីនេះ ហើយបានកសាងជាអាស្រមឡើងនៅក្នុងឆ្នាំ១២២៥ និងបានដាក់ឈ្មោះទីនេះថា “សូភាស”*។ រឿងព្រេងទាំងពីរនេះស្តាប់ទៅមិនសូវទំនងនឹងប្រវត្តិឈ្មោះ “សូភាស” នេះឡើយ ហើយយើងក៏ពិបាកក្នុងការកំណត់ឈ្មោះនេះដែរ។ ក្នុងភាសាសំស្ក្រឹតពាក្យ “**សុភាស**” មានន័យថា “**ពន្លឺចែងចាំងដ៏ស្រស់ស្អាត**”។ ចំណែក នៅក្នុងសិលាចារឹកដែលរកឃើញនៅវត្តសូភាស គេបានរៀបរាប់អំពីឈ្មោះស្រែមួយនៅក្បែរៗប្រាសាទមានឈ្មោះថា “**ភាស្ករវិនិ**”[២] ដែលជាប្រភេទឈ្មោះចេញពីភាសាសំស្ក្រឹតប្រែថា “**ម្ចាស់ព្រះអាទិត្យ**”។ ឈ្មោះ “**ភាស្ករ**” ប្រសិនបើយើងអានរបៀបខ្មែរនឹងកាត់សល់ខ្ទីត្រឹម “**ភាស**”។ ប៉ុន្តែ យើងក៏ពិបាកជឿថា **សូភាស** ក្លាយមកពីឈ្មោះក្នុងសិលាចារឹកនេះដែរ។ មួយវិញទៀត បើយើងពន្យល់តាមពាក្យខ្មែរ “**ភាស**” មានន័យថា ស្ទឹង ព្រែក ប្រឡាយ អូរ បឹង (ឧទាហរណ៍៖ **ស្ទឹងភាស** នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង) ប៉ុន្តែពាក្យនេះខ្មែរស្ទើរលែងប្រើនៅតំបន់ផ្សេងទៅហើយ។ ពាក្យ “**ភាស**” ដែលមានន័យទាក់ទងនឹងអាងស្តុកទឹក ទំនងត្រូវន័យដើមជាងពាក្យភាសដែលចេញពីសំស្ក្រឹត ព្រោះដូចរៀបរាប់ខាងលើថា នៅជុំវិញវត្តសូភាស មានហ៊ុមព័ទ្ធដោយអាងស្តុកទឹកធំៗ ដូចជា ទន្លេអុំ ត្រពាំងស្រង់ ត្រពាំងព្រះ ។ល។

---

[១] Aymonier 1900: 243; Lajonquière 1902: 176; Parmentier 1927: 200.

[២] Coedès 1954: 6.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ផ្តែរទ្វារនៅវត្តសូភាសនៅសល់ មាន ៤ ផ្ទាំង ដែលគេយកទៅចាក់ស៊ីម៉ង់ត៍តម្រៀបគ្នានៅជ្រុងអាគ្នេយ៍ព្រះវិហារថ្មី (រូបលេខ១)។ ផ្តែរទ្វារទាំងនេះ ធ្លាប់បានសិក្សាដោយអ្នកស្រាវជ្រាវមកពីអឺរ៉ុបជាច្រើនរូបមកហើយ ជាពិសេស គឺលោកស្រី Mireille Bénisti[៣] កាលពីឆ្នាំ១៩៧៤ និងលោក Jean Boisselier[៤] កាលពីឆ្នាំ១៩៦៨។ ក្នុងនោះ មានផ្តែរទ្វារចំនួន ៣ ដែលស្ថិតនៅក្នុងសម័យកាលតែមួយ ពោល គឺផ្តែរទ្វាររចនាបថសំបូរព្រៃគុក។[៥] ផ្តែរទីមួយ មានទម្រង់ដូចផ្តែរទ្វារនៅតំបន់សំបូរព្រៃគុកសុទ្ធសាធតែម្តង ដែលដូចនឹងផ្តែរទ្វារតួប៉ម S2, S10, S11, S17-6, N11, N14, N15, Z1 ។ល។ ផ្តែរទ្វារនេះ មានចម្លាក់រូបសត្វមករ (សត្វតំណាងឱ្យទឹក និងជាយានជំនិះព្រះភិរុណនិងព្រះនាងគង្គា) នៅចុងខាងបែរមុខចូលក្នុង ខ្ជាក់សត្វតោនិងក្បាច់បន្ទាត់ធ្នូមានរាងកោង (*toraṇa*) ដែលនៅកណ្តាលមានចម្លាក់ព្រះឥន្ទ្រជិះដំរី (ទេពនៃផ្គរ រន្ទះ ទឹកភ្លៀង) អមដោយចម្លាក់ទេពជិះសេះ (*Aśvin* និង *Marut*) (រូបលេខ២)។ ចំពោះផ្តែរមួយទៀត (ផ្តែរទីពីរ) មានលក្ខណៈស្ទើរដូចគ្នានឹងផ្តែរទីមួយដែរ គ្រាន់តែចម្លាក់ជាច្រើនមានការលុបបាត់ជាងផ្តែរទីមួយ ពោល គឺជាផ្តែររចនាបថសំបូរព្រៃគុកដូចគ្នា (រូបលេខ៣)។

ចំណែក ផ្តែរទីបីវិញ គឺមានលក្ខណៈប្លែកពីផ្តែរផ្សេងៗទៀតក្នុងរចនាបថសំបូរព្រៃគុក ពោល គឺអាចចាត់ទុកបានថាជាផ្តែរមានតែមួយគត់ក្នុងស.វ.ទី៧ (រូបលេខ៤)។ ផ្តែរនេះមានចម្លាក់សត្វមករបែរមុខចូលក្នុងខ្ជាក់សត្វតោនិងក្បាច់បន្ទាត់ធ្នូរាងកោង ហើយនៅចំកណ្តាលមានចម្លាក់ព្រះឥន្ទ្រគង់នៅលើដំរីដូចផ្តែរទាំងពីរខាងលើដែរ ប៉ុន្តែនៅអមសងខាងចម្លាក់ព្រះឥន្ទ្រពុំមានចម្លាក់ទេពជិះសេះ (*Aśvin* និង *Marut*) ឡើយ ហើយគេជំនួសវិញដោយរូបនាគរាជ (*Nãga-rãja*) ដែលជាទូទៅយើងធ្លាប់ឃើញតែឆ្លាក់ដាក់នៅខាងចុង ដោយជិះលើសត្វមករ ឬដាក់តែឯងនៅខាងចុង ឧទាហរណ៍ ផ្តែរនៅសារមន្ទីរខេត្តកំពង់ធំ (រូបលេខ៤) ផ្តែរប្រាសាទព្រះធាតុរកា (រូបលេខ៥) ផ្តែរប្រាសាទព្រៃក្មេង នៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង (រូបលេខ៦)។ ក្រៅពីនេះ នៅខាងក្រោមចម្លាក់ព្រះឥន្ទ្រ និងចម្លាក់នាគរាជ សិល្បករលម្អដោយរូបរាហូខ្ជាក់កម្រងផ្កា ដែលករណីបែបនេះ យើងធ្លាប់ឃើញមាននៅលើផ្តែរប្រាសាទភ្នំដើងព្រៃ (ភ្នំធំ) ប៉ុន្តែផ្តែរនោះ គេលម្អក្រោមព្រះឥន្ទ្រប៉ុណ្ណោះ ពុំមានលម្អរាហូបីតម្រៀបគ្នាបែបនេះឡើយ (រូបលេខ៧)។ លើសពីនេះ យើងឃើញនៅក្រោមសត្វមករ គេមានលម្អចម្លាក់រាហូនៅលើក្បាលសសរទាំងសងខាងផងដែរ ដែលលក្ខណៈ

---

[៣] Bénisti 1974: 159-160.

[៤] Boisselier 1968: 130.

[៥] Bénisti 1974: 159-160.

បែបនេះដូចនឹងផ្តែរខាងលិចនៃប្រាសាទយាយព័ន្ធ តួប៉មS1 (រូបលេខ៨)។ ការឆ្លាក់រូបរាហូនៅលើផ្តែរទ្វារក្នុងសិល្បៈមានការពេញនិយមខ្លាំងណាស់ ដូចយើងធ្លាប់ឃើញមុនដំបូងនៅលើផ្តែរប្រាសាទប្រាំបីល្វែង នៅតំបន់ថាឡាបរិវ៉ាត់ និងបន្តគ្រប់សម័យកាលរហូតដល់បច្ចុប្បន្ន ដ្បិតគេយល់ថា រាហូ គឺនិមិត្តរូបតំណាងឱ្យការ"កើត"និង"ស្លាប់"[៦] ហើយនៅក្នុងព្រហ្មញ្ញសាសនា រាហូ គឺជាអសុរដែលបានលួចផឹកទឹកអម្រឹតដែលកើតចេញពីការកូរសមុទ្រទឹកដោះមុនគេ តែត្រូវព្រះវិស្ណុគប់នឹងកងចក្រដាច់ត្រឹមករាហូ ធ្វើឱ្យករបស់រាហូមានជីវិតអមតៈ។[៧]

ដោយឡែក ផ្តែរទីបួន គឺជាផ្តែរស្ថិតនៅចុងរចនាបថព្រៃក្មេង ដើមរចនាបថកំពង់ព្រះ ដែលមានលក្ខណៈកម្រខ្លាំងណាស់ (រូបលេខ៩)។ ការដែលថាកម្រនេះ គឺមកពីផ្តែរទ្វារនេះមានចម្លាក់រូបគ្រុឌនៅចំកណ្តាល ព្រោះក្នុងរចនាបថកំពង់ព្រះ ការលម្អរូបគ្រុឌនៅចំកណ្តាលបែបនេះមានតែផ្តែរទ្វារនៅវត្តសូភាសដែលកំពុងសិក្សានេះ និងផ្តែរទ្វារមួយទៀតរកឃើញនៅខេត្តអាត់តឺពើ[៨] ប្រទេសឡាវប៉ុណ្ណោះ (រូបលេខ១០)។ នៅជួរកណ្តាល យើងឃើញសិល្បករលម្អជាក្បាច់ផ្កាភ្ញីទេសតម្រៀបឆ្លាស់គ្នាខណ្ឌចែកដោយរូបគ្រុឌនៅចំកណ្តាល តែខាងចុងគួចវង់ចូលក្នុងដូចទម្រង់ផ្តែររចនាបថកំពង់ព្រះដទៃទៀតដែរ។ លោក Jean Boisselier យល់ឃើញថា ផ្តែរទីបួនដែលរកឃើញនៅវត្តសូភាសនេះ ជាផ្តែរអន្តរកាលរវាងរចនាបថកំពង់ព្រះ និងរចនាបថគូលែន។[៩]

ក្រៅពីនេះ នៅសល់តែទ្វារចំនួន ១ ទៀត ដែលសព្វថ្ងៃបានបាត់បង់ពីទីតាំងដើមហើយ តែធ្លាប់មានសិក្សាដោយលោកស្រី Mireille Bénisti កាលពីឆ្នាំ១៩៧៤ (រូបលេខ១១)។ ផ្តែរនេះមានអាយុកាលដើមរចនាបថកំពង់ព្រះ ពោល អាចចុងស.វ.ទី៧ ដើមស.វ.ទី៨ ហើយមានទម្រង់ក្បាច់ដូចផ្តែរវត្តជើងឯក[១០] និងផ្តែរទ្វារមួយចំនួនទៀតនៅក្នុងរចនាបថកំពង់ព្រះ។

## តើផ្តែរទាំងអស់នៅវត្តសូភាស មានអាយុកាលដូចម្តេចខ្លះ?

តាមទិន្នន័យដែលបានពីសិលាចារឹកប្រាសាទវត្តសូភាស (K.115) នៅផ្នែកខាងលើជាភាសាសំស្ក្រឹតបានរៀបរាប់អំពីការប្រតិស្ឋានលិង្គព្រះឥសូរ នៅក្នុងថ្ងៃ៩កើត ខែជេស្ឋ មហាសករាជ ឆ្នាំ៥៨៧ វេលាម៉ោង ១១ព្រឹក[១១] ពោល គឺត្រូវនឹងគ្រឹស្តសករាជ ឆ្នាំ៦៦៥ ហើយត្រូវនឹងរជ្ជកាលរបស់

---

[៦] Ang Choulean 2006: 85-96.
[៧] Thomas 1999: 93.
[៨] Lorrillard 2014: 208.
[៩] Boisselier 1968: 93.
[១០] Bénisti 1974: 160.
[១១] កំ វណ្ណាក់ ២០១៩: ៤២។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ព្រះបាទជ័យវរ្ម័នទី១ (គ.ស.៦៥៧ - ៦៨១)។ ដូច្នេះ ប្រភពពីសិលាចារឹកអាចឱ្យយើងដឹងថា នៅគ.ស.៦៦៥ នៅប្រាសាទវត្តសូភាស ធ្លាប់មានការប្រតិស្ឋានលិង្គ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី១។ ប៉ុន្តែផ្តែរទីមួយ ទីពីរ ទីបី ដែលយើងបានរៀបរាប់ខាងលើហាក់ពុំសូវស៊ីគ្នាជាមួយ ផ្តែរក្នុងរាជ្យរបស់ទ្រង់ដែលគេរកឃើញនៅតំបន់ផ្សេងទៀតឡើយ ដ្បិតផ្តែរភាគច្រើនក្នុងរាជ្យព្រះអង្គច្រើនតែផ្តែរទ្វារដែលស្ថិតនៅរចនាបថព្រៃក្មេងប៉ុណ្ណោះ។ ម៉្លោះហើយ យើងសន្និដ្ឋានបានថា ផ្តែរចំនួន ៣ ដែលយើងរៀបរាប់ដំបូង អាចមានអាយុកាលចាស់ជាងគ.ស.៦៦៥ ពោល គឺអាចនៅដើមស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧) ឬ ព្រះបាទភវវរ្ម័នទី២ (គ.ស.៦៣៧-៦៥៧)។ ដោយឡែក ផ្តែរទី៤ និងផ្តែរទី៥ (បាត់បង់ពីទីតាំងដើម) អាចជាផ្តែរដែលស្ថិតនៅក្រោយអាយុកាលនៃការប្រតិស្ឋានលិង្គ ពោល គឺអាចមានអាយុកាលនៅចុងស.វ.ទី៧ ដល់ចុងស.វ.ទី៨ (ចន្លោះចុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ដល់រជ្ជកាលព្រះនាងជ័យទេវី)។

ជារួមមក សិលាចារឹក វត្ថុសិល្បៈជាច្រើន និងផ្តែរទ្វារទាំងអស់ដែលស្ថិតនៅវត្តសូភាស ជាតឹកតាងសបញ្ជាក់ឱ្យឃើញអំពីការប្រណិប័តន៍ព្រហ្មញ្ញសាសនាដ៏មុតមាំនៅចន្លោះដើមស.វ.ទី៧ ដល់ចុងស.វ.ទី៨ បើទោះបីសព្វថ្ងៃប្រាសាទទាំងបីតួប៉មនៅវត្តសូភាសបានដួលរលំអស់ទៅហើយក៏ដោយ៕

## ឯកសារយោង


**កំ វណ្ណាវ៉ា**

២០១៩, *ប្រជុំសិលាចារឹកខេត្តកំពង់ចាម*, ភ្នំពេញ

**Ang, Chouléan**

2004, "La mort-renaissance en abstraction iconograhphique", *UDAYA*, *Numéro 5*, Phnom Penh

**Aymonier, Etienne**

1900, *"Le Cambodge"*, *Tome I, Le royume actuel*, Paris.

**Bénisti, Mireille**

1974, Recherches sur le premier art khmer, VI. Linteaux inéits et linteaux méconnus, *Art Asiatique*, Tome 30, Paris

**Boisselier, Jean**

1968"Les linteaux khmère du VIII$^{e}$ siècle, Nouvelles données sur le style de Kampong Preah ", *Arlibus Asiae*, Tome XXX, Paris

**Coedès, George**

1954, *Inscription du Cambodge*, Vol VI, Hanoi

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Michael, Lorrilard**

2014, Pre-Angkorian communities in the middle Mekong valley (Laos and adjacent areas, in the N. Revire & S.A. Murphy (eds.) *Before Siam: Essays in Arts and Archaeology*. River Books/The Saim Society: Bangkok

**Parmentier, Henri**

1927, *"L'Art Khmér Primitif"*, Tome I, Paris

**Thomas, Paul**

1999, *"Epics, Myths and Legends of India*", Treasure House of Books, Boombay.



រូបលេខ១៖ ផ្តែរទីមួយនៅវត្តសូភាស ខេត្តកំពង់ចាម (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ២៖ ផ្តែរទីពីរនៅវត្តសូភាស ខេត្តកំពង់ចាម (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៣៖ ផ្តែរទីបីនៅវត្តសូភាស ខេត្តកំពង់ចាម (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ២៤៖ ផ្តែរមិនស្គាល់ប្រភពនៅសារមន្ទីរខេត្តកំពង់ធំ (រូបថត៖ លួន ទីឃា)



រូបលេខ២៥៖ ផ្តែរប្រាសាទព្រះធាតុរកា ខេត្តកំពង់ធំ



រូបលេខ២៦៖ ផ្តែរប្រាសាទព្រៃក្មេង សព្វថ្ងៃនៅសារមន្ទីរជាតិហ្គីមេ បារាំង (រូបថត៖ ហួន យ៉ារ)



រូបលេខ២៧៖ ផ្តែររកឃើញនៅប្រាសាទភ្នំដើងព្រៃ ឬភ្នំធំ (រូបថត៖ ថៃ ឈាងម៉េង)



រូបលេខ២៨៖ ផ្តែរទ្វារបញ្ឆោតខាងលិចប្រាសាទយាយព័ន្ធ តួប៉ម S1 (សព្វថ្ងៃតាំងនៅសារមន្ទីរជាតិភ្នំពេញ)



រូបលេខ២៩៖ ផ្តែរទី៤ នៅវត្តសូភាស (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ ផ្តែររកឃើញនៅខេត្តអាត់តឺពើ ប្រទេសឡាវ (រូបថត៖ EFEO Photograhic archives, Fonds Laos,21928, dated 1903))



រូបលេខ១១៖ ផ្តែរទី៩ នៅវត្តសូភាស (សព្វថ្ងៃបាត់បង់ពីទីតាំងដើមហើយ) (រូបថត៖ Bénisti, 1974)

អរិយធម៌ខ្មែរ
KHMER CIVILIZATION